**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៨៧១ ចទ.៣.៤១-៩៧

**សារាចរ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ផ្ញើជូន**

**លោកប្រធានតុលាការគ្រប់ជាន់ថ្នាក់**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការធ្វើលិខិតថ្កោលទោសនិងបញ្ជីស្រង់ស្ថិតិសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរ ឬសេចក្តីចម្លងសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរ ។

ខ្ញុំសូមជម្រាបលោកថា កន្លងមកមានតុលាការខ្លះដូចជាតុលាការខេត្តកំពង់ឆ្នាំងនិងពោធិសាត់ជាដើមបានប្រព្រឹត្តបំពានលើមាត្រា១២ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលដោយហ៊ានចេញលិខិតថ្កោលទោសខុសពីសមត្ថកិច្ចដែលច្បាប់បានកំណត់ ។

តុលាការមួយមិនអាចដឹងអំពីសាលក្រុមព្រហ្មទណ្ឌសម្រេចដោយតុលាការ ឯទៀតទូទាំងប្រទេសនោះទេ មានតែនាយកដ្ឋានព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ទេដែលមានបញ្ជីសាលក្រមព្រហ្មទណ្ឌទូទាំងប្រទេស អាចដឹងថាជនណាខ្លះត្រូវបានតុលាការផ្តន្ទាទោស ។

អាស្រ័យដោយក្រសួងត្រូវការធ្វើបញ្ជីសាលក្រមទូទាំងប្រទេសនេះហើយ បានជាក្រសួងបានទាមទារឱ្យតុលាការទូទាំងប្រទេសធ្វើបញ្ជីស្រង់ស្ថិតិសាលក្រមនិងសាលដីកាព្រហ្មទណ្ឌស្ថាពរ ចាប់ពីពេលតុលាការកើតឡើងរហូតមកដល់ដំណាច់ឆ្នាំ១៩៩៦ និងចម្លងសាលក្រមសាលដីកាព្រហ្មទណ្ឌស្ថាពរចាប់ពីដើមឆ្នាំ១៩៩៧ ផ្ញើមកក្រសួង ។

បញ្ហាធ្វើបញ្ជីស្រង់ស្ថិតិសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរ និងចម្លងសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរផ្ញើមកក្រសួងយុត្តិធម៌នេះ ក្រសួងបានណែនាំច្រើនលើកច្រើនសាររួចមកហើយ តាមលិខិតលេខ៖

-១១៦ ចទ.៩៥ ចុះថ្ងៃទី៣១-១-៩៥

-១០៩៩ រប.៩៥ ចុះថ្ងៃទី០៥-១២-៩៥

-១១៩ ចទ.៤៩៦ ចុះថ្ងៃទី៣០-១-៩៦

-១៣៥២ រប.៩៦ ចុះថ្ងៃទី០២-១២-៩៦

ប៉ុន្តែលោកប្រធានតុលាការ មួយចំនួននៅតែមិនបានយកចិត្តទុកដាក់អនុវត្តតាមការណែនាំខាងលើនេះទេ នេះជាការមើលស្រាលដែលក្រសួងមិនអាចអត់ឱនឱ្យតទៅទៀតបានឡើយ ។ បើអស់លោកត្រូវការបុគ្គលិកជួយការងារថែមទៀត ក្រសួងនិងផ្តល់ក្រមខណ្ឌបន្ថែមឱ្យ ប៉ុន្តែកុំមានៈចិញ្ចឹមទុកការខ្វះខាតនេះតទៅទៀត។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**